ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១០ ព្រឹក នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រ**កម្ពុជា** និង **ឯកឧត្តម ស្យុង ប៉** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើគម្រោងនៃមូលនិធិពិសេសមេគង្គ-ឡានឆាង ដែលមានទឹកប្រាក់សរុបចំនួន **៧.៣១៥.៩០៨ ដុល្លារអាមេរិក** សម្រាប់អនុវត្តគម្រោងកម្ពុជា **ចំនួន ១៦** នៅក្នុងបញ្ជីគម្រោងដំណាក់កាលទី១ ។

គួរកត់សំគាល់ថា ស្ថិតក្រោមក្របខ័ណ្ឌមូលនិធិពិសេសមេគង្គ-ឡានឆាង គម្រោងចំនួន ១៦ ដូចខាងក្រោម ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី៣ កាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៧ នៅទីក្រុង**តាលី** ប្រទេស**ចិន** ។

១. កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍព្រះពុទ្ធសាសនា និងសិក្ខាសាលាស្តីពីប្រសិទ្ធភាពនៃ ការគ្រប់គ្រងពុទ្ធសាសនាថេរវាទទៅតាមបណ្តាប្រទេសទន្លេមេគង្គ

២. សិក្ខាសាលាបណ្តុះបណ្តាលមេគង្គ-ឡានឆាង និងផ្សព្វផ្សាយស្តង់ដាទេសចរណ៍ នៃសហគមន៍អាស៊ាន

៣. ការវិចវិលដី និងការលើកកម្ពស់ជីវភាពរស់នៅតាមមូលដ្ឋាន តាមរយៈការគ្រប់គ្រងដីប្រកបដោយនិរន្តភាព

៤. ការស្តារឡើងវិញព្រៃឈើ និងការលើកកម្ពស់ការប្រើប្រាស់ព្រៃឈើប្រកបដោយចីរភាព នៅអាស៊ីអាគ្នេយ៍

៥. ការលើកកម្ពស់ប្រសិទ្ធិភាព នៃការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់នៅក្នុងបណ្តាប្រទេសទន្លេមេគង្គ ដែលមិនបានចុះបញ្ជីត្រឹមត្រូវ ដើម្បីការគ្រប់គ្រងផលផលប្រកបដោយនិរន្តភាព

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

៦. អ្នកស្ម័គ្រចិត្ត ICT មេគង្គ-ឡានឆាង

៧. លើកកម្ពស់ការតភ្ជាប់ចរាចរណ៍អាកាសនៅកម្ពុជា ឡាវ មីយ៉ាន់ម៉ារ និងចិន

៨. ការលើកកម្ពស់ការស្រាវជ្រាវ និងកិច្ចសន្ទនា ស្តីពីកិច្ចសន្យាកសិកម្មនៅតាមបណ្តាប្រទេសមេគង្គ-ឡានឆាង

៩. ការអភិវឌ្ឍន៍សហគមន៍ចម្រុះតាមបណ្តាដងទន្លេមេគង្គ

១០. ការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទក្នុងប្រទេសកម្ពុជា

១១. សន្និសីទមេគង្គ-ឡានឆាង ស្តីពីសហគ្រាសវប្បធម៌ធុនតូច និងមធ្យម

១២. ការទប់ស្កាត់ការលួច ការជីក ការនាំចូលនាំចេញខុសច្បាប់តាមតំបន់មេគង្គ-ឡានឆាង

១៣. ប្រព័ន្ធត្រួតពិនិត្យគុណភាពទឹកនៅតាមដងទន្លេមេគង្គ និងការបង្កើតមជ្ឈមណ្ឌលព័ត៌មាន

១៤. ការស្រាវជ្រាវរួម និងការអភិវឌ្ឍន៍បច្ចេកវិទ្យានៅក្នុងការវិនិច្ឆ័យហានិភ័យ ការតាមដានត្រួតពិនិត្យ និងការបង្ការជាមុននូវជម្ងឺគ្រុនឈាម

១៥. ការបង្កើនការការពារមេគង្គ-ចិន និងកម្មវិធីកិច្ចសន្ទនាគោលនយោបាយ និង

១៦. កម្មវិធីគាំទ្រសម្រាប់ឱកាសទទួលបាននូវអាហារូបករណ៍ចំពោះនិស្សិតក្រីក្រ សម្រាប់ការសិក្សាលើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅប្រទេសចិន ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៧